Khmer Story Lovers

# ពេជ្ឈឃាដ

ប្រលោមលោកប្រឌិតតាមសម័យបុរាណ ចិន

## ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ



ប៉ាយវាន់ផានតំហាត:

-យីអើ ! ចៅតើផល់ណាទៀត ? ដោយសារតែអំពើថោកទាបរបស់ឯង នាគគ្វើងជាគ្រូត្រូវដាច់ដៃម្ខាងទៅ ។ លោកបង់ហ្វឹងមានគុណលើឯងធ្ងន់ដូចភ្នំ ហេតុឯងមិនចេះអៀនខ្មាស ?

មាណពមិនយល់ទាល់តែសោះ ក៏សួរទៀត:

- នាគគ្វើងណា ? លោកបង់ហ្វឹងជានរណា ខ្ញុំឥតស្គាល់ទេ ។ ហេតុអីគាត់ដាច់ដៃម្ខាងដោយសារខ្ញុំ? អំពើស្អីថោកទាប ហើយខ្ញុំប្រព្រឹត្តពីអង្កាល់ ?

ប៉ាយវាន់ផានហួសចិត្តណាស់ព្រោះស៊ឹផានមិនព្រមសារភាពៗ គេបង់ឲ្យគាត់លាតត្រដាងអំពើថោកទាបនៅក្នុងទឹកកក កណ្ដាលហ្វឹងជូរេចៈឬ ?

កូនស្រីគាត់ឈឺចិត្តរហូតលោកសម្លាប់ខ្លួនទៅហើយ គាត់ឃើញមុខស៊ឹផានយូរ រឹតតែខឹងឡើង ទ្រាំមិនបាន ហូតដាវខ្វាក វាលាស់វឹប ! រូបសិតក្នុងស្រោមវិញភ្លាម ៗ ។ បន្ទាប់មកគាត់បន្ទុលសសរ ស្រែកខ្លាំង ៗ :

-សុំបងប្អូនមើលឲ្យច្បាស់ ! ក្រុមភ្នំទឹកកកមានយុទ្ធសិល្ប: គុនដាវតិចតួចមិនអាចបង្ហាញអស់លោកទេ ។ ប៉ុន្តែដាវទាំងអម្បាលម៉ាន តែកាប់របស់អ្វីហើយ តែងទុកស្នាមកាំជូចផ្កា

អ្នកប្រែសម្រួល: អ.គីមសាន

តម្លៃ

ផ្សាយចេញពីក្រុមអ្នកនិពន្ធ
«មាតុភូមិ»
ភ្នំពេញ

លេខ ១៣

ទឹកកកផងនិង ។ ព្រោះហេតុនេះហើយបានជាក្រុមបក្សយើងមានឈ្មោះក្នុំទឹកកក ។

ទាំងអស់គ្នាមៀងក្នុកមើលសសរ ឃើញស្លាមងាវបីកន្លែងមានរាងជាផ្កាទឹកកកតំរៀបស្មើ ប៉ាយរ៉ាន់ផានហួតងាវណាស់អម្បាញ់មិញរហ័សណាស់ គ្មានឧរណាស្មានថា គាត់អាចកាប់ស

ទុកស្លាមក្រឡៅដូច្នេះទេ ។

កាលឃើញវ៉ុនរ៉ាន់យីខ្លាតប៉ះទ្វារជែកគេឥតយកចិត្តទុកដាក់ទីងក្រុមក្នុំទឹកកកឡើយ, ពេល ឃើញស្លាដៃ ប៉ាយរ៉ាន់ផាន ម្ដងវិញគេស្ងៀមសរសើរផ្លាក់មាត់គ្រប់គ្នា, មានខ្លះស្រែកហោទៀតផង ប៉ាយរ៉ាន់ផានពោល :

– ខាងក្នុំទឹកកកមានអ្នកខ្លាំងពូកែលើសខ្ញុំច្រើនទៀត ។ ខ្ញុំបង្ហាញប៉ុណ្ណេះ មិនមែនបា ន័យថា ខ្ញុំអួតទេ គឺខ្ញុំសុំមិត្តទាំងអស់ជួយធ្វើសាក្សីក្នុងរឿងមួយ ។ ត្បិតប្រាំពីរឆ្នាំមុន យើងខ្ញុំមា សិស្សចង្រៃម្នាក់ឈ្មោះ ស៊ុផុងយីថ្វើមធំណាស់, វាហ៊ានប្រយុទ្ធសាកល្បងជាមួយគ្រូមាខ្សែ ។ គ្រូ បានប្រដៅវាដោយកាប់ដើងទ្រូងវាប្រាំមួយងាវ ទុកស្លាមផ្កាទឹកកក ដូចអស់លោកឃើញលើសសរនេ ស្រាប់ ។ វិជ្ជាគុនងាវប្រចាំក្រុមយើងមិនប្លែកពីគេទេ តែខ្ញុំហ៊ានអះអាងថាក្នុងលោកយើងនេ គ្មានក្រុមបក្សណាក៏មិនអាចទុកស្លាមរបួសមានរូបរាងផ្កាទឹកកកដូចពួកយើងដែរ ។ ស៊ុផុងយី ឯងលាក់ការពិតទុកធ្វើអី ស្មានថាគេគេមិនឃើញឬ ? ឥឡូវឯងហ៊ានលាត់ដើងខោបង្ហាញ គ្រប់គ្នាមើល តើមានស្លាមងាវប្រាំមួយរាងផ្កាទឹកកកឬទេ ?

មាណពស្លូរដោយក្ដៅល់:

- លោកចង់ឲ្យខ្ញុំមួរដើងខោឬ ?

– ហ្នឹងហើយ ! បើដើងឯងគ្មានស្លាមរបួសទេយើងទទួលទោសជាមនុស្សខ្វាក់ យើងសំពះសុំទោ លោកមាយក្រុមក្ងាម ។ តែបើដើងឯងមានស្លាមរបួសមែន.. តើឯងគិតយ៉ាងម៉េច ?

មាណពស្មើច :

– បើដើងខ្ញុំមានស្លាមរបួសប្រាំមួយកន្លែងមែន ខ្ញុំគិតថាចំឡែកណាស់ ព្រោះខ្លួនខ្ញុំឥតដឹងសោះ ប៉ាយរ៉ាន់ផានទំសម្លឹងមុខឆាយក័យក្ដុកក្ដាក់និកថា:

– ផននេះពិតជាអាស៊ុផុងយីហើយទោះបែកគ្នាប៉ុន្មានឆ្នាំផ្លាស់ប្តូរបន្តិចបន្តួចក៏ដោយ ផ្ទៃមុខ នៅដដែល ។ ប្អូនហួបានបញ្ជាក់ប្រាប់យើងថាពិតជាអាហ្នឹងហើយ, តើពួកយើងអាចប្រ

កើតដែរឬ ?

នៅពេលគាត់សញ្ជឹងគិតនោះឈិនលុងជីខាងក្រុមឈានលួសើចហាសា:

- លោកចង់មើលជើងនាយក្រុមយើង ឯនាយក្រុមយើងក៏ប្រហែលចង់មើលជើងអ្នកខាងហ្នឹងដែរ ៗ កន្លែងនេះមនុស្សច្រើនណាស់មិនគួរលាត់ជើងខោបង្ហាញគ្នាទេ, បើទៅក្នុងបន្ទប់ដេកប្រហែលសមជាង !

ប៉ាយវ៉ាន់ជានខឹងតូងបង្វិលខ្លួនស្ទុះដល់កណ្តាលបន្ទប់ស្រែកគំហក :

- ស៊ីជុងយី ! អាតោជេឡៅខ្ទង ! បើមិនហ៊ានបញ្ចេញស្នាមរបួសទេ ត្រូវទៅភ្នំទឹកកកជាមួយយើងភ្លាម !

ពោលចប់ ហួតជាវលោស់ខ្ទាប់ , ស៊ុផាឌពោល :

- សូមលោកប៉ាយកុំអាលខឹងប្រទេញតពេក ៗ លោកថាខ្ញុំមានរបួស ខ្ញុំថាឥតមានទេ , សុំអ្នកលល់គ្នាជួយមើលសិន ៗ

ពោលហើយនាយលើកជើងឆ្វេង, លូកដៃម្ខាងចាប់លាត់ខោ ៗ បន្ទប់ទាំងមូលស្ងាត់ជ្រៀបព្រោះម្នាក់ ៗ ប្រឹងអត់ដង្ហើម ផ្តោតខ្សែភ្នែកមើលជើងមាណព .... ស្រាប់តែគេឈាន់មាត់ យី ! ដោយអាការៈភ្ញាក់ផ្អើល ៗ

ត្បិតលើជើងឆ្វេងមាណពមានស្នាមរបួសដូចផ្កាទឹកកកប្រាំមួយច្បាស់ក្រឡែតមិនអាចប្រកែកបាន ៗ ក្នុងចំណោមអ្នកទាំងអស់ មាណពភ្ញាក់ផ្អើលជាងគេ, លូកដៃជូតស្នាមរបួសញាប់ស្អែកតែរបួសដុះចេញពីសាច់ពិតក្រឡេវហើយជូតម្តេចបាន ? មាណពឆ្ងល់មហាឆ្ងល់ខំញីភ្នែកពិនិត្យម្តងទៀតហើយងើបមើលសសរឃើញច្បាស់ជាស្នាមដាវពង់ផ្កាទឹកកកមានប្រាំមួយជ្រុងដូច ៗ គ្នា ៗ

សិស្សភ្នំទឹកកកទាំង ៩ នាក់សម្លឹងមាណពមិនដាក់ភ្នែក រង់ចាំស្តាប់នាយទទួលទោស ៗ មាណពបែកញើសតក់ៗកាន់ជើងខោញ័រធ្មឹង , ដៃម្ខាងអង្អែលជើងថ្នម ៗ នឹកថា បើមានស្នាមរបួសនេះម៉េចខ្លួនឥតដឹងសោះ ? ឬមួយ ... ឬមួយខ្លួនក្មេងរឿងដែលកន្លងហួសអស់មែន ?

មាណពងឿងឆ្ងល់ហួសវិស័យ បែរមើលតៃហស៊ុស្សូរយោបល់ ៗ គ្រូពេទ្យដៃឯកត្រីក្បាលមួយ ១ , មាណពងាកមើលវ៉ាងតុងម្តងឃើញនាងលៀនអណ្តាតដាក់ ទីបំផុតនាយងាកមើលវ៉ាងមិនហួសបីម្តង ឃើញគាត់លើកដៃបញ្ចេញម្រាមពីរឲ្យទៅមុខជាសញ្ញាវាយប្រហារ ៗ ក្នុងពេលជាមួយគ្នានោះ ឈិនលុងជីហុចដាវឲ្យនាយព្រមទាំងនិយាយប្រាប់:

- លោកនាយក្រុមកុំផ្ដេកយូរពេក, ប្រឡងថ្វីដៃគ្នាម្ដងទៅ ! អ្នកណាឈ្នះអ្នកនោះត្រូវ, អ្នកណាចាញ់អ្នកហ្នឹងខុស ។

ឈុនជីឃើញប៉ាយវ៉ាន់ផានប្រើគុនផាវរហ័សរហួនពេកថា ប្រហែលគាត់គ្មានកម្លាំងកាយ នាយក្រុមស៊ីទេ ។ បើឃើញភស្តុតាងជាក់ស្ដែងម្ល៉ឹងហើយ នៅប្រកែកបានការអី មាន ប្រយុទ្ធគ្នា ? ប្រសិនបើលោកនាយក្រុមមិនឈ្នះគេ ក្រុមឈានលួសម្លាប់ពួកក្នុងទឹកកកកុំឲ្យស មួយជាការស្រេច ។

មាណពទទួលផាវតាំងរើរ៉េយ, ប៉ាយវ៉ាន់ផានពោលមួយៗច្បាស់ៗថា :

-ស៊ីផុងយ៉ីស្លាប់យើងណា ! យើងទទួលបញ្ជាពីលោកគ្រូធំនៃវិមានទឹកកកយកជំរះគំនុំផ្ទាល់ តាក់ទងនឹងក្រុមឈានលួទេ ដូច្នេះយើងមិនត្រូវប្រយុទ្ធគ្នានៅទីនេះឡើយ ។ យើងសុំបបួ ឯងទៅជំរះបញ្ហាខាងក្រៅវិញ តើឯងយល់យ៉ាងណាដែរ?

មាណពវង្វេងស៊ុនសួររើយ:

-យើង ... យើងជំរះបញ្ហាអី ?

ខណៈនោះទីងគុងវេញខ្ញងនាយថ្មមៗខ្ទប:

- បងឆាន ! ចូលប្រយុទ្ធនឹងគេភ្លាមទៅ, បងមានកម្លាំងច្រើនយុទ្ធសិល្បៈខ្ពង់ខ្ពស់, ច សម្លាប់គេទៅរួចការហើយ ។

មាណពសួរ:

- ម៉េចឲ្យខ្ញុំសម្លាប់គេ ? គេមិនមែនមនុស្សអាក្រក់ឯណា ?

ពោលបណ្ដើរនាយដើរទៅមុខបណ្ដើរ ។ ប៉ាយវ៉ាន់ផានក្រឡេកមួយភ្នែកស្គាល់សមត្ថ មាណពភ្លាមក៏មិនហ៊ានប្រហែស ព្រោះអម្បាញ់មិញនាយគ្រាន់តែលោសដៃការវ៉ុនវ៉ាន់យីប៉ុងខ្វាត រេចូសយ៉ាងជំណាំទៅហើយ ។ គាត់លោសស្លៃជាវវិប ១ ចេញពន្លឺព្រាត ពីខ្លួនប្រាណមាណ ដុំដិត ។ ស៊ុផានព្រិលភ្នែកលែងមើលអ្វីឃើញក៏ភ័យផ្អើលមួយរំពេច មិនដឹងធ្វើម៉េចក៏ តែគ្រវាសដៃគ្រប់ទិសដំបន់ ។

មិនយូរប៉ុន្មានប៉ាយវ៉ាន់ផានកាច់ដៃការនាយផាច់ពីដុំ ហើយមាណពចាប់អារម្មណ៍ត្រជាក់ស្រ ត្រង់បំពង់ក គឺបុងផាវសិស្សក្នុងទឹកកកបានផាក់ផ្ដាប់គល់កនាយស្រេច ។ អម្បាញ់មិញនាយ

រលាស់ដៃអាវខ្លាតរុនវ៉ាន់យ៉ើផាការចែងឡេ, ពេលនេះនាយភ័យស្រាប់ ហើយប៉ាយវ៉ាន់ផានពូកែ ស្មៀតវ៉ាវផង ទើបបរាជ័យយ៉ាំងគាប់ហើសប្បុរេះ ។

## វគ្គទី ១៣

## បងប្អូនភ្នំទីភកភក

ក្នុងពេលអន្ធយស្មៀម ប៉ាយវ៉ាន់ផានសង្កេតសមាជិកខាងក្រុមឈានល្អដឹងថា សត្រូវមានគ្នាច្រើនណាស់ ហើយមានអ្នកខ្លាំងពូកែជាពិសេសដូចតៃហៃស៊ី និងតាចាស់ស្មៀកខោខ្វី ដែលឈរពីក្រោយស៊ុំផានជាដើម ។ ពេលនេះគាត់មិនហ៊ានបន្ទង់ទេ. ស្ទុះចូលក្លែងលួកដៃឆ្វេងចាប់ទុចបង្កេះមាណពជាប់ បំរើនកម្លាំងធាតុខ្លាស់ផីពចរពីរកន្ទេងរួចស្រេច ទើបស្រែកខ្លាំង ៗ :

- ចាំថ្ងៃក្រោយយើងមកសុំទោសអស់លោកណា !

ទីវ៉ាន់ផីនឃើញបងរួមគ្រូមានជ័យជំនះ ក៏មិនបង្អង់យូរចាប់លើកវុនវ៉ាន់យ៉ើគ្រាក់ក្លាម ហើយវ៉ាយសម្រុកសំដៅមាត់ទ្វារ ។ លបិនឈុងជី និងនីហ៊ុងយេយារកាំបិតស្រែកព្រមគ្នាៈ

-លែងលោកនាយក្រុមយើងភ្លាមមក !

ហើយយារកាំបិតកាប់ស្ទាកាប់ជើងប៉ាយវ៉ាន់ផានយ៉ាំងសាហាវ ។ អ្នកក្លាហានទាំងសទត្តរលាស់អាវខ្លាប់ពួតឹង ១, គ្រប្រយុទ្ធក្ដាក់ត្រឹតរៀងខ្លួន ខ្លាតទៅក្រោយមួយជំហានម្នាក់ ។ ប៉ាយវ៉ាន់ផានទឹកថា ពីរនាក់នេះពូកែដល់ម៉ឹងទៅហើយ, បើពួកគេព្រួតគ្នាចូលមក បងប្អូនយើងទាំង ៩ ច្បាស់ជាហោលសាប់ហោលភ្លឺងនៅទីនេះមិនខាន ។ ជាបន្ទាន់នោះគាត់បង្អើរខ្លួនទៅឈរផ្អែកជញ្ជាំងតំកម :

-ស៊ុំជុងយីធ្លាក់ក្នុងកណ្ដាប់ដៃខ្ញុំហើយ,ឲ្យតែនរណាហ៊ានចូលមកខ្ញុំសម្លាប់វ៉ាចោលភ្លាម !

សមាជិកក្រុមឈានល្អតក់ស្លុតថា នាយក្រុមត្រូវគេចាប់បានដោយងាយដូច្នេះសោះ ព្រោះគេឃើញគាត់ពូកែគ្រាន់បើដែរ ។ ពេលនេះគេស្រឡាំងកាំងមើលមុខគ្នាមិនមាំង, សូម្បីទីងមិនហួសបីដែលមានការពិសោធន៍ច្រើនក៏មិនយល់បុព្វហេតុដែរ ។ គាត់ងាកមើលទៅស្រីឃើញនាងភ័យស្លុតធ្វើសញ្ញាឲ្យជួយផងតែតាចាស់យល់ផ្សេងថាៈ

- អាប្រមក់នេះពូកែខ្លាំងណាស់ , ដូចកាលនៅលើទូកយើងសាកល្បងនឹងវ៉ារួចហើយ , ម្ដេច

បណ្ដោយឲ្យគេចាប់ឆាយៗ ម៉្លេះ ? ក្រែងវាមានគោលបំណងអ្វីមួយស្ងាត់កំបាំង ដែលពួកយើងមិន ដឹងណា ! បើដូច្នេះវាក្រែងខូចគ្រោងការ ចាំវាកាត់អន់ចិត្តទេដឹង ? ចាំលបមើលឲ្យច្បាស់បន្តិ សិន ។ ចិនគុនឃើញលោកតាធ្វើបា នាងធូរស្រាលក្នុងចិត្តបន្តិច តែនាងនៅបារម្ភជាមិ ចំពោះវាសនាសង្សារ ។

ពេលនោះទីវាន់ជីនកំពុងចំរើនកម្លាំងប្រាណក្លាដៃកញ្ច្រឹក ១, តៃហាស៊ីស្ទុះចូលទៅស្រែក :

– សូមអស់លោកកុំហេនពេក, ចាំខ្ញុំប្រើគេឲ្យបើក ។

ហ្វូវាន់ជីតហាក :

– បៀសចេញ !

ពោលហើយគ្រវីដាវញាប់ស្លែកលបកោរតោរទីវាន់ជីន ។ តៃហាស៊ី លូកដៃចាប់ផ្លែដាវនាង នាងក្ដាក់ព្រើតនឹកថា : តាប៉ុនេះមិនខ្លាចដាវទេដឹង ?

ក្នុងគ្រាអាក់ខានមួយដង្ហើមនេះ តៃហាស៊ីធ្វើដៃក្ដុកដូចចំពក់ចាប់ដាវ ហើយក្ដាប់ដៃ ផ្លែដាវនាងហួ ៗ រ៉ុង ! ដៃនាងវាន់ជីបែកឈាមរហាម, ដាវរបូតជ្រុះដល់ដីលាន់តឹង ។ តៃប៉ាំង ឆ្ងៀតពេលទះដីពចរនាងជាំងដួលគ្រង ។ កាយវិការអស់នេះប្រព្រឹត្តទៅយ៉ាងរហ័សក្រៃលែងមិ ចាញ់ប៉ាយវាន់ជានដៃយហូតដាវកាប់សសរប៉ុន្មានទេ ។

ចិនមិនហួសបីសសើរថាស្នៀតឈ្មោះ ក្រាំគុណទឹងប្រាំមួយ គ្រាន់បើអីចឹង បានជាល្បីល្បាញ ណាស់ ។

តៃហាស៊ីបង្កើនខ្លួនក្លិបភ្លែតដូចអំពិលអំពែក ទះផងចុចដីពចរផង វាយផ្ដួលសិស្សក្នុងកក ប្រាំពីរនាក់ជាបន្តបន្ទាប់គ្នា ។ ម្នាក់ៗអាចទប់ទល់នឹងគាត់បានត្រឹមបីបួនស្នៀតប៉ុណ្ណោះ ។ ប៉ាយវាន់ជានស្រែកសរសើរ:

– អស្ចារ្យមែន ! អស្ចារ្យ ! ចាំថ្ងៃក្រោយខ្ញុំសុំសាកល្បងស្នៀត « ក្រាំគុណទឹងប្រាំមួយ » ម្ដង ។

ពោលចប់ចុចចុងជើងស្ទុះវិដល់ដំបូល បែកក្បឿងប្រាវ ១ ។ គាត់ស្ពាយស៊ីផានចេញ តាមប្រហោងដំបូលបាត់ ។ តៃហាស៊ីស្រែកតប :

– មិនបាច់ចាំថ្ងៃក្រោយទេ !

ពេលផងហក់ទៅតាមផង ។ តែរំពេចនោះតាទ្វីហារ៉ាប់រយកោមខ្លួនគាត់ជិតជុំ ដោយប៉ាយភន់ផានត្រីពីលើមក ។ តៃហៃហាស៊ីទៅក្នុងលំហអាកាសហើយផងតអាវុធទៅផែផង ក៏ប្រែស្នៀតទម្លាក់ខ្លួនមកក្រោមវិញ ។ ស្នៀតនេះសាហាវណាស់ បើមិនមានខ្លួនខុសពិតពិតអាចត្រូវរបួសបាន ព្រោះពេលគាត់ហក់ឡើង គាត់ប្រើកម្លាំងច្រើនពេក ។ តឡូវតៃហៃហាស៊ីចុះដល់ក្រោមវិញដោយសុខសប្បាយ តែប៉ាយភន់ផានចាប់ខាយក្រុមរត់បាត់ទៅហើយ ។

លោកគ្រូពេទ្យមិនអស់ចិត្តទន្ទ្រាំដើរឡើងលើដំបូលដេញតាមទៀត ។ ទីងតុងភ័យណាស់ចង់ លោតតាមដែរ តែទីងមិនហួសបីចាប់ដៃនាងជាប់ឲ្យប្រាប់:

- កុំប្រញាប់ពេកទៅស្រី !

ខណៈនោះ ឮស្នូរផាំងៗប្រាវ គឺក្បឿងធ្លាក់មកក្រោមព្រោះសិស្សភ្នំទឹកកកម្នាក់ស្ទួមផ្ដិត ដែលដេកផ្ទួលមួយរយៈពេលដោយសារតៃហៃហាស៊ីនោះស្ទុះក្រោកភ្ញាក់រត់ចេញតាមដំបូលរហ័សដូចសត្វស្វា ។

ឈិនឈុងជីនៅជិតនោះស្រាប់ ក្រវាសកាំបិតវិបដាច់បាតស្បែកជើងជននោះខាំងផ្គាំងរិះកំប៉ុកជើង ។ អ្នកកាល់គ្នាស្រឡាំងកាំងមិននឹកស្មានថា ក្រៅពីប៉ាយភន់ផាន នៅមានសិស្សខ្លះរហ័សរហួនពិតៗកែងលំម្ដឹងសោះ ព្រោះជនសំគមនេះត្រូវលោកគ្រូពេទ្យចុចជីពចរដេកស្ដឹកទៅហើយ នៅអាចប្រើនកម្លាំងស្ទុះលោតតាមដំបូល ក្រោមក្រសែភ្នែកសមាជិកក្រុមឈានលួនទៀត ! ទីហ៊ុនយេខ្ទាចប្រាំពីរនាក់ខាងភ្នំទឹកកករត់ដែរ ក៏ដើរទៅចុចជីពចរថែមមួយកន្លែងម្នាក់ភ្លាម ។ សមាជិកក្រុមឈានលួនឯទៀត ចែកគ្នាដេញតាមប៉ាយភន់ផាន តាមដំបូលរោងខ្លះ តាមផ្លូវក្រោមខ្លះ ។ ម្នាក់ៗនឹកថា :

- គេមករករឿងដល់ទីកន្លែងព្រមទាំងចាប់លោកខាយក្រុមបានទៀត, បើមិនចំដណ្ដើមមកវិញក្រុមឈានលួនអស់ហាននឈរឈ្មោះក្នុងពិភពគុកលៀតហើយ ។ ឲ្យតែឃើញជនក្រគូលប៉ាយនៅត្រង់ណា, ហើយឡោមព័ទ្ធភ្លាមពិតជាអាចរំដោះលោកខាយក្រុមបានមិនខាន ។

គេរត់រកគ្រប់ច្រកប្រវែងហាសិបយោជន៍ជុំវិញ រហូតមេឃភ្លឺស្រាងៗ នៅតែមិនឃើញស្រមោលប៉ាយភន់ផានទៀត ។

ចំណែកប៉ាយភន់ផានស្ពាយស៊ុយធានរត់បណ្ដើរ នឹកបណ្ដើរ :

ហើងមិនស្មានថា ការចាប់ខាយក្រុមនេះដោយស្រួលយ៉ាងហ្នឹងសោះ ។ លទ្ធផលនេះ

ចាត់ទុកជាល្អបង្គួរ ទោះបានរោយយៃតែឲ្យកំរោយ. ប៉ុន្តែក្រុមឈានល្អមិនមែនស្ងៀមទេ គេមុខ
ចាត់គ្នាកាយសំណាញ់ស្វែងរកយើងមិនខាន ។

ប៉ាយវាន់ជានតោលភ្លែកសម្លឹងទៅឆ្ងាយ ឃើញស្ពានថ្មមួយដូចសត្វនាគលាតសន្ធឹងលើទឹកស្ទឹង គាត់មិនបាច់ពិចារណា ស្ទុះរត់សំដៅស្ពានយ៉ាងរហ័ស, ដៃម្ខាងស្ពាយស៊ុំផាទនដៃម្ខាងកាន់ដងដាវជាប់ ទៅដល់នោះភ្លាម គាត់យារដាវអស់ទំហឹងលោតវ៉ឹងទៅក្រោមស្ពានបុកផ្ទៃដាវជាប់ក្នុងសាច់ថ្ម គេ ស្ងៀម ។ មិនយូរប៉ុន្មានក្រុមឈានល្អមកដល់មែន, . គេស្រែកឆ្លើយឆ្លងគ្នាពីម ស៊ីងម្ខាងទៅម្ខាង, អ្នកខ្លះឆ្វេងស្ពានគគ្រឹកគគ្រេងសឹងជ្រុះដាវប៉ាយវាន់ជានពីសាច់ថ្ម ។ វាន់ជ សម្រេចចិត្តហើយថាបើគេឃើញ, គាត់នឹងប្រហារមាណពភ្លាម ។ ពេលនោះក្រុមឈាន ដើរឆែកឆេរតាមឆ្នេរស្ទឹងរៃកកាយស្មៅខ្ចៅខ្ចី ... ស្រាប់តែឃើញស្រមោលមួយ ហក់ភ្លែតពីគុម្ព រត់ទៅទិសខាងកើតលឿនស្ទើរ ។

ប៉ាយវាន់ជានឃើញប៉ុណ្ណោះ ស្គាល់ជាក់ជាប្អូនរួមគ្រូគាត់ឈ្មោះវុនវ៉ាន់យីដែលចេះគុនសម្រា ខ្លួនពូកែជាងគេ ។ អាកប្បកិរិយានេះពិតជាកលល្បិចសម្រាប់ដេញឆ្ងាយពីសំបុក ដើម្បីទុ ពេលឲ្យគាត់រំដោះខ្លួនរត់ហើយ ។ មែន! ភ្លាមនោះក្រុមឈានល្អឃើញស្រមោលគេស្រែ ប្រាប់គ្នាដេញតាមក្រោយ, ប៉ាយវាន់ជាននឹកថា ពួកនេះមិនមែនល្ងង់ទាំងអស់គ្នាទេ ច្បាស់ជាម អ្នកខ្លះរត់មកកន្លែងដែលវិញឥឡូវហ្នឹង ។ គិតយ៉ាងណាឲ្យផុតគ្រោះថ្នាក់ ?

គាត់សម្ងំគិត ស្រាប់តែឮសម្លេងផងរៃវប៉ះទឹកគ្រូកគ្រាកៗ...ក្រឡេកទៅឃើញទូកឥតដំបូលបីកម្រ មកសន្សឹមៗ ។ ទូកពីរផ្ទុកសុទ្ធតែបន្លែនិងផ្លែឈើសព្វសារពើ, ទូកទីបីដាក់សុទ្ធតែចំបើង គឺជាទូកអ្នកស្រុកយានតូវ ដឹកអីវ៉ាន់ទៅលក់ឯផ្សារ ។ ប៉ាយវាន់ជានត្រេកអរណាស់រង់ចាំតែ ដែរទូកដល់ក្រោមស្ពានក៏ដកដាវចេញពីរលោកប្រូងលើគំនរចំបើងជាមួយស៊ុំផាទ ហើយសម្ងំស្ងៀម ម្ចាស់ទូកឥតដឹងទេ បេះតែបន្តដំណើរដល់ទីដៅ ទើបអែបទូកចូលច្រាំង នាំគ្នាឡើងគោករស់

ប៉ាយវាន់ជានសម្ងំស្តាប់មួយភ្លែត ទើបលើកដាវក្នុងស្រោមលោតចេញពីគំនរចំបើងឡើងលើ គោក ។ គាត់ក្រឡេកទៅខាងលិចឃើញទូកដំបូលខ្មៅមួយយ៉ាងធំ ក៏ម្នីម្នារត់ទៅរកដែ ទាំងលូកប្រាក់មួយដុំបោះលើទូកស្រែកថា :

– អ៊ឺម្ចាស់ទូក! មិត្តខ្ញុំម្នាក់នេះមានជម្ងឺដុះដាបណាស់ សុំជួយចម្លងខ្ញុំទៅកាន់ទីប្រជុំជនខា

មុខល្បឿនឡើង ។

ម្ចាស់ទូកឃើញថ្លៃប្រាក់ត្រេកអរណាស់ ចាប់ផ្ដើមចែវអុំទូក ។ ប៉ាយវ៉ាន់ថានចូលពួនក្នុងទូកព្រោះដីផងជាដំបន់រស់នេះស្ថិតនៅក្រោមការត្រួតត្រារបស់ឈានគុយ ។ គាត់នៅតែគិតថាចាប់បានខាងក្រុមគេម្នាក់មែន តែបងប្អូនយើងប្រាំពីរនាក់ធ្លាក់ក្នុងកណ្ដាប់គេ, ថ្ងៃណាអាចចេញវិញបាន ? ហើយយ៉ាងណាអាចជួយរួច ?

គាត់បារម្ភម៉្យាងទៀតខ្លាចស៊ីផងបានភ្ញាក់ក៏លើកចុងជីពចរគាយថែមពីរបីកន្សែងទៀត, ទំរាំដល់ទីប្រជុំជនគាត់ចុបជីពចរស៊ីផងបានស្ទើរគ្រប់កន្សែង ។ ពេលនោះគាត់ស្រែកប្រាប់ម្ចាស់ទូក :

-អ៊ីបងប្រុស ! ចេះតែអុំបណ្ដោយទឹករហូតទៅណា៎ ខ្ញុំជូនប្រាក់ថែមទៀតកុំភ័យ ។

ម្ចាស់ទូកឆ្លើយ :

-សូមថ្លែងអំណរគុណចំពោះសន្ដានចិត្តលោកម្ចាស់តែទូកខ្ញុំតូចពេក ក្រែងទ្រាំទ្រមិនដល់សមុទ្រ សុំអែបច្រាំង បានទេលោកម្ចាស់?

-បាន! អែបច្រាំងខាងលិចចុះ ។

ទូកល្បឿនលយតាមបណ្ដោយខ្សែទឹកមួយស្របតកធំទៀត ទើបឃើញផ្ទាំងពណ៌លឿងលិចៗនៅឯឆ្ងាយ ។ ប៉ាយវ៉ាន់ថានក្រោកឈរក្បែរក្ដោងរួចពុសម្លៀកក្លួតបរិញជាបន្ទាន់ ។ គាត់បញ្ជាម្ចាស់ទូក:

- អែបច្រាំង !

ម្ចាស់ទូកទាញចង្កូតចូលច្រាំងមិនទាន់ស្រាវជ្រាវប្រាកដផង ស្ពានឲ្យអ្នកដំណើរឆ្លងផង ស្រាប់តែប៉ាយវ៉ាន់ថានស្ទុះ «អ្នកជម៉ឺ» លោតឡើងដល់ច្រាំងស្រេច ។ ទៅដល់ដីគោកមានមនុស្សមួយហ្វូងតែលឹងតរមកចន្លោះស្រែកហៅកញ្ចៀវយ៉ាងរកាយ ។

ក្បួនជននេះជាក្រុមទីពីរខាងក្នុងកក ឃើញប៉ាយវ៉ាន់ថាន ចាប់បានមាណពម្នាក់រូបស្លៀកពាក់ស្អាតបាតគេសួរលាន់ : បងប៉ាយ, នេះគឺជា . . .

ប៉ាយវ៉ាន់ថានចាប់មាណពយ៉ាងខ្លាំងទៅដីពោលទាំងកំហឹង:

- ប្អូនចាំងអស់ឃើញទេ ? ទីបំផុតបងចាប់បានហោរាជើងចំណុចបំណាង ។ ប្អូនពលគ្មានស្គាល់វាទេឬ ?

គេនាំគ្នាទុកសង្កេតស៊ីផានមួយសន្ទុះ ឃើញមុខមាត់មាណពនេះ ប្រហែលកុមារក្បាលខ្ញ
ឈ្មោះស៊ីផុនយី ដែលធ្លាប់ហាត់រៀនយុទ្ធសិល្បៈនៅវិមានទឹកកក ក៏ខឹងក្រេវក្រោធរៀនខ្លួនដេរស្ដីតាម
លាន់ទ្រហឹង ខ្លះលើកជើងទាត់ , ខ្លះស្ដោះទឹកមាត់ថ្វាក់ , ម្នាក់ទៀតមានឋានៈធំជាងគេស្រែកថា

– ពួកយើងកុំធ្វើបាបវាពេក ប្រយ័ត្នលោកគ្រូយកទោស ។ លោកបងប៉ាយប្រតិបត្តិកា
លើកនេះបានលទ្ធផលល្អប្រសើរគួរកែកាយណាស់ ។

ប៉ាយវ៉ាន់ជានគ្រវីក្បាល :

– បងចាប់បានគាត់នេះមែន , តែប្អូនៗប្រាំពីរនាក់ធ្លាក់ក្នុងកណ្ដាប់ដៃគេទុកដូចជាខាតវិញទេ
ទាំងអស់គ្នានាំស៊ីផានទៅកាត់ទោសមួយកញ្ចាស់ដែរឥតមនុស្សថ្លៃក្បាលឡើយ ។ ពីនេះ
កន្លែងពួកគេស្នាក់អាស្រ័យមួយផងមួយ យាមក្នុងការពារកាត់ងគ្នា ។ គេរៀបចំបាយទឹកឲ្យប៉ាយវ៉ាន់ជា
ហើយពិភាក្សាគ្នាអំពីរឿងចាប់នាយក្រុមឈានល្អ ។

ប៉ាយវ៉ាន់ជានពោលមុនគេ :

– យើងចាប់បានអាល្អិតនេះហើយ ត្រូវបញ្ជូនវាទៅជូនលោកនាយក្រុមគាត់ទោស, រីឯ
ប្អូនទាំងប្រាំពីរនាក់ដែលធ្លាក់ក្នុងកណ្ដាប់ដៃសត្រូវនោះប្រហែលពុំមានគ្រោះថ្នាក់ដល់ជីវិតទេ ព្រោះ
ពួកឈានល្អមិនហ៊ានសម្លាប់ឡើយ ។ លោកប្អូន ចាង, ប្អូនវ៉ូងនិងប្អូនចាវនៅជំរំនេះស្រា
សុំជួយស៊ើបដំណឹងបងប្អូនយើងផង ! កុំធ្វើផ្ដេសផ្ដាសណា !

ជនទាំងបីងក់ក្បាលយល់ព្រម ។ ប៉ាយវ៉ាន់ជានពោលបន្ត :

–ប្អូនទាំងបីត្រូវចិតចំ យ៉ាងណាចាក់ចងនិងប្អូនវុនវ៉ាន់យីឲ្យបាន ហើយស្ដាប់បញ្ជាគេទាំងអស់ព្រោះ
គេមានតម្រិះច្រើន, មានប្រាជ្ញវាងវៃ,កុំសំគាល់ថាគេជាប្អូនរួមគ្រូទៅភ្លេងភ្លាងដាក់គេខូចការអស់ណា !

បុរសត្រកូលចាង,វ៉ូងនិងចាវធ្លាប់គោរពកោតខ្លាចបងរួមគ្រូត្រកូលប៉ាយណាស់ក៏ងើយបាទព្រមគ្នា

ប៉ាយវ៉ាន់ជានពោលបន្ត:

– ចំណែកពួកយើងឯទៀតត្រូវដើរវាងទន្លេឈានការ ត្រឡប់ទៅភ្នំទឹកកកវិញ ទោះផ្លូវឆ្ងា
បន្តិចក៏កុំរញេរ , ព្រោះតាមស្មានក្រុមឈានល្អមិនទៅរកយើងដល់នោះទេ ។

សំដីគាត់បញ្ជាក់ប្រាប់ប្អូនៗ នូវការញញើតក្រុមឈានល្អជាក់ស្ដែងណាស់ , គាត់ឥតល
លៀមទេ ។ លុះមេឃងងឹតគាត់ផ្ដួចផ្ដើមពោលទៀត :

- ពួកយើងចាកចេញពីភ្នំទឹកកកមកលើកនេះ បានដុតភូមិឋានសាំងស៊ូខ្ទេចជាផេះ ហើយចាប់បានអាចារ្យស៊ីផុងយីមែន ។ តែលោកប្អូនស៊ុនទិនជូស្លាប់បង់ជីវិត ហើយប្អូនទិនធ្លាក់ក្នុងកណ្ដាប់ដៃសត្រូវជាមួយប្អូនឯទៀតឃើញថាវេទនាណាស់ ។ រូបសេចក្ដីមកតឹបងខ្វះសមត្ថភាពដឹកនាំពួកយើងមិនត្រូវរបៀបបានជាធ្លាយការអ៊ីចង់ ។

ពេលនោះសិស្សម្នាក់ឈ្មោះហ៊ូវ៉ាន់យានបញ្ចេញយោបល់ថា :

- សូមលោកបងប៉ាយកុំបន្ទាបខ្លួនពេក ។ ដើមហេតុមិនមែននៅត្រង់ហ្នឹងទេ, មកពីបងប្អូនយើងហាត់រៀនគុនវិជ្ជាមិនបានដិតដល់ណា ! មើល ! , ក្រៅពីបងហ្វុងនិង លោកបងប៉ាយមាននរណាហាត់រៀនយុទ្ធសិល្បៈរបស់លោកគ្រូផងលង់ទីទៅ ?

សិស្សម្នាក់ទៀតរាងធាត់កន្ទុលឈ្មោះ មិនវ៉ាន់ហ្វូបន្ទរថា :

- កាលយើងប្រឡូកប្រយុទ្ធលើភ្នំទឹកកកយើងនាំគ្នាស្មានថា ពូកែណាស់ ។ ដល់ចេញដើរក្នុងពិភពគុនទើបឃើញច្បាស់ថានៅខ្វះច្រើនណាស់ ។ លោកបងប៉ាយអ្ហា ! ពួកយើងត្រូវចាំមេយង់នឹកមែនទែនទើបហ៊ានចេញដំណើរ, ហេតុនេះក្នុងពេលទំនេរសូមលោកបងជួយបង្ហាត់ពួកយើងប៉ុន្មានស្នៀតផង ។

អ្នកឯទៀតយល់ស្របតាមសេចក្ដីស្នើ, ប៉ាយវ៉ាន់ផានតបថា:

- លោកឪពុកបង្ហាត់សិស្សដូច ៗ គ្នាឥតមានស្នៀតម្ខាង ៗ ឡើយ ។ ប្អូនទាំងអស់គ្នាមើលបងហ្វុង ? គាត់ខំហាត់ហ្វឹកហ្វឺនខ្លួនឯងស្ងៀមណាស់ , ឥឡូវពូកែជាងបងផង ។

មិនវ៉ាន់ហ្វូបន្ត:

- អ៊ីចឹងហើយលោកបង ! អ្នកណាក៏ដឹងច្បាស់ថាលោកគ្រូឥតមានស្រឡាញ់មួយស្អប់មួយដែរ ប៉ុន្តែពួកយើងល្ងង់ខ្លៅពេកបានជាមិនសូវយល់មិនសូវចេះចាំ ។

ប៉ាយវ៉ាន់ផានសម្រេច:

- ក្នុងដំណើរទៅភ្នំទឹកកកពិតជាមានឧបសគ្គខ្លះមិនខាន គប្បីយើងហាត់យុទ្ធសិល្បៈបណ្ដើរ ៗ ឲ្យកើតដៃ ។ ឥឡូវសុំប្អូនហ៊ូនិងប្អូនមិនសាកល្បងគ្នាមុនទុកឲ្យប្អូនចាវនិងវ៉ូងទៅយាមខាងក្រៅ , បើមានហេតុភេទមិនស្រួលឆាប់ឲ្យដំណឹងភ្លាម ។

ចាវនិងវ៉ូងចង់ឲ្យបងរួមគ្រូពន្យល់ណែនាំថែមដែរ គេចង់នៅមើល តែបងបញ្ជាដូច្នេះហើយគេមិន

ហ៊ានប្រកែកនាំគ្នាដើរទុយមុយទៅយាម ។

ហ៊ូវ៉ាន់យ៉ានខឹង មិនវ៉ាន់ហ៊ូមានកម្លាំងព្រឹសហូតដាវចេញភ្លាម ។ មិនវ៉ាន់ហ៊ូត្រូវជាប្អូនលើកដៃ

គោរពពោលមុន :

- សូមលោកបងហ៊ូកុំលេងធ្ងន់ដៃពេក ។

ហ៊ូវ៉ាន់យ៉ានគោរពប៉ាយវ៉ាន់ផាន :

- សូមរៀមច្បងជួយតម្រែតម្រង់ផង ។

ប៉ាយវ៉ាន់ផានងក់ក្បាល ។ ហ៊ូវ៉ាន់យ៉ានរលាស់ដាវរឹបចាក់តម្រង់ស្មាឆ្វេង មិនវ៉ាន់ហ៊ូតាម

ស្ទៀតដាវនៃភ្នំទឹកកកឈ្មោះ «មែកផ្កាទទឹងដើម» ។ នៅលើភ្នំទឹកកកមានសុទ្ធតែបុប្ផាគ្រប់

ប្រភេទ ; គេហាត់ស្ទៀតគុនតាមទ្រង់ទ្រាយផ្កាទាំងអស់ ។ ហេតុនេះហើយបានជាសិស្សទាំង

ពីរសាកល្បងគ្នាចុះឡើងឃើញតែពន្លឺដាវភ្លៀលភ្លាត់ដូចផ្កាទឹកកករបុីតតាមខ្យល់ ឬ ដូចមែកផ្កាទោរទន់

បង្អួតគ្នា ។

ស៊ីផានត្រូវប៉ាយវ៉ាន់ផានចុចជីពចរតាំងពីដំបូងតំរើកខ្លួនឥតរួចទេ ។ ពេលនេះនាយត្រូវពួក

ទឹកកកគ្រវែងទៅកៀនជញ្ជាំងកុំទឹកនាឃ្លានបាយស្ទើរបោចពោះ ។ នាយឮគេដដែកគ្នាច្បូរវែ

កំបើកភ្នែកក្រឹះ ៗ មើលគេសាកល្បងយុទ្ធសិល្បៈដើម្បីបន្ទប់ ។ មាណពមានកម្លាំងកាយស្កុកស្គ

ស្រាប់ហើយធ្លាប់ចាប់សត្វក្នុងព្រៃតាំងពីតូចមកថែមទាំងហាត់រៀនយុទ្ធសិល្បៈព្រះរូបបង្រ្កាបបិសាចទាំង

ដប់ប្រាំបី ទៀតឃើញថានាយអាចក្លាយជាអ្នកគុនខិយមកំពូលបានយ៉ាងងាយ ។

ពេលនេះមាណពមិនទាន់ដឹងខ្លួនជាតូក, មិនទាន់ចេះប្រើកម្លាំងតាមកាលៈទេសៈ កំសន្តេ

មើលសិស្សភ្នំទឹកកកកាំង ។ មុនដំបូងឃើញគេចាក់ទៅចាក់មកញាប់រន្ថើនព្រមទាំងហាក់លោ

បែបស្រាលទៀតផង ។ មួយសន្ទុះទៀតនាយយល់ថាសិស្សពីររូបនេះកំប្លែងលេងទៅវិញ

ព្រោះនាយចើសភ្នែកណាស់ ។ នាយពិហារណាថា បើនាយខាងណេះរុញដាវថែមឲ្យខ្លាំងបន្តិច

អាវុធនោះនឹងប៉ះដៃគូដូចបំណង ។ ប៉ុន្តែគេមិនរុញ ប្រហែលគេមិនហ៊ានធ្វើឲ្យរបួសបងប្អូន

ក្រុមទេដឹង ?

មិនយូរប៉ុន្មានប៉ាយវ៉ាន់ផានស្រែកថាឈប់ ហើយស្ទុះមកយកដាវពីហ៊ូវ៉ាន់យានដោយពោល :

- មួយស្ទៀតអម្បាញ់មិញនេះ ឯងមិនចេះប្រើកម្លាំងកាយទេ ។ បើរុញថែមទៅមុ

បន្តិចឯងទទួលជ័យជំនះភ្លាម ។

សុីផាននា ប៉ាយវ៉ាន់ផានពោលស្របគំនិតខ្លួនដូច្នោះសប្បាយរីករាយណាស់ ហើយនឹកថា :

-លោកប៉ាយនិយាយត្រូវមែន ឲ្យតែបាក់បន្ថែមបន្តិចទៀតទៅ ឈ្នះបាត់ទៅហើយ ចុះហេតុអ្វីលោកគ្រូហ៊ូមិនព្រមរុញដាវឲ្យខ្លាំង ?

ហ៊ូវ៉ាន់យានងក់ក្បាលសារភាព :

-ការយល់ឃើញរបស់បងប៉ាយសមហេតុផលណាស់ ប៉ុន្តែស្នៀត «ខ្យល់បក់ផ្កាភោយ» អម្បាញ់មិញបញ្ចេញអស់កម្រិតតែប៉ុណ្ណេះ ព្រោះខ្ញុំគ្មានកម្លាំងគ្រប់គ្រាន់នឹងរុញដាវបន្ថែមទៅទៀតបានទេ ។

ប៉ាយវ៉ាន់ផានញញឹម :

- ការហាត់រៀនយុទ្ធសិល្បៈកម្លាំងធាតុមិនមែនជាការងាយស្រួលទេ បើតាមយោបល់បង យុទ្ធសិល្បៈកម្លាំងធាតុនៃក្រុមបក្សយើងខ្ទន់ខ្សោយណាស់ តែយើងអាចយកស្នៀតគុនដាវមកប៉ះប៉ូវបាន ទោះស្នៀតនេះយកទៅប្រៀបផ្ទឹមនឹងស្នៀតដាវនៃក្រុមសៅលីនជី, យុនលុន អ៊ូតាំង ម៉ៃអើ ដែលមានអាយុកាប់រយឆ្នាំមិនបានក៏ដោយ ក៏អាចចាត់ទុកថាវិសេសវិសាលល្មមប្រើការដែរ ។ ដូច្នេះនៅពេលជួបសត្រូវ យើងត្រូវផ្អែកលើស្នៀតគុនដាវ មិនគួរប្រើកម្លាំងធាតុដើម្បីវាយលុកទេ ទើបអាចសង្ឃឹមទទួលជ័យជំនះខ្លះ ។

អ្នកទាំងពីរស្តាប់ចប់ ងក់ក្បាលយល់ស្របថានិយាយត្រឹមត្រូវមែន ។

តាមពិតម្ចាស់វិមានទឹកកកប៉ាយជីតាយ ជា «លោកគ្រូកិត្តិយស» មានកម្លាំងស្ទុកស្ដម្ភដូចហាក់ ហាហុកសិបឆ្នាំនោះដោយសារកាលពីក្មេងគាត់មានភ័ព្វបានលេបថ្នាំពិសេសសម្រាប់លើកកម្លាំងតែប៉ុណ្ណោះ ។ បើតាមកម្រិតនៃយុទ្ធសិល្បៈកម្លាំងធាតុរបស់វិមានទឹកកក ថាមពលគាត់មិនអាចស៊ុសង់នឹងអ្នកគុននិយមជំពូកបានឡើយ ។ អាស្រ័យថ្នាំពិសិដ្ឋ គាត់ក៏ក្លាយទៅជាតារាពិភពគុន ហើយល្បីថាមានកម្លាំងកាយវិសេសណាស់ ។ តែសិស្សជំនាន់ក្រោយទាំងអស់តែងខ្វះលក្ខណៈនេះជានិច្ច ។

លោកគ្រូកិត្តិយសមានចិត្តរឹងរូសណាស់ គាត់មិនដែលបង្ហើបចំណុចខ្សោយនៃយុទ្ធសិល្បៈរបស់ខ្លួនប្រាប់សិស្សទេ ម្ល៉ោះហើយ ពួកសិស្សដែលនៅហាត់ហ្វឹកហ្វឺនតែលើកំស្ពានខុសថា យុទ្ធសិល្បៈរបស់ខ្លួនមានលក្ខណៈគ្រប់គ្រាន់ ទើបពេលចេញដើរក្នុងពិភពគុនពួកគេទទួលបរាជ័យជាបន្តបន្ទាប់ហើយបានប៉ាយវ៉ាន់ផាននិយាយប្រាប់តាមត្រង់ ក៏ភ្ញាក់ដឹងខ្លួនរាល់គ្នា ។ បន្ទាប់មកប៉ាយ

រ៉ន់ជានសំដែងស្នៀតគុនដាវបើតានិងជួយកែតម្រូវប្អូនទាំងអស់ ។

ពេលនេះគាត់បញ្ជាឲ្យហ៊ូរ៉ន់យាន និង មិនរ៉ន់ហូចេញទៅយាមជំនួសសិស្សត្រកូលចាវនិងវ៉ូងម្តង ។ សិស្សភ្នំទឹកកកមានការពិសោធន៍ខ្វះ១ ហើយ គេយល់ថា ស្នៀតនីមួយៗដែលហាត់រៀនមិនបានជ្រៅជ្រះ អាចនាំមកនូវគ្រោះថ្នាក់ដល់ជីវិត ហេតុនេះនៅពេលរៀមច្បងប៉ាយពន្យល់ គេនាំគ្នាស្តាប់យ៉ាងប្រុងប្រយ័ត្នមិនដូចកាលនៅភ្នំទេ ។

ប្អូនរួមគ្រូរ៉ន់ជាន ចេញមកប្រយុទ្ធដោយប្រើស្នៀតប៉ៃកៗគ្នា ។ ចំណែកស៊ុំផានដែលមានកម្លាំងធាតុជាមូលដ្ឋានដ៏មាំមួន កាន់តែល្អតលាស់ខាងវិស័យយុទ្ធសិល្បៈជាលំដាប់ អាស្រ័យប្រាជ្ញាបានវៃផ្ចាល់និងសេចក្តីពន្យល់របស់ប៉ាយរ៉ន់ជាន ។

ផឡូវងល់វេនសិស្សទីប្រាំពីរនិងទីប្រាំបីប្រកួតគ្នាម្តង ស៊ុំផានយល់ស្នៀតគុនដាវទាំងនេះខ្វះ១ហើយ ។ ថ្វីត្បិតតែមិនស្គាល់ឈ្មោះអស់ តែការប្រែប្រួលនិងអត្ថន័យដ៏ទូលំទូលាយនៃស្នៀតនីមួយៗ នាយចេះគ្មានសល់ ។ ឲ្យតែម្នាក់យារដាវចាក់នាយប្រញាប់ប្រញាល់នឹករបៀបរកការការពារខ្លួនភ្លាម ហើយ ស្នៀតដែលនាយបង្កើតនោះ ជួនកាលខ្ពង់ខ្ពស់ជាងស្នៀតផ្ទាល់របស់ក្រុមភ្នំទឹកកកទៅទៀត ។ ការកែប្រែតម្រង់របស់ជនត្រកូលប៉ាយចំពោះប្អូន ១ ច្រើនប្រហាក់ប្រហែលនឹងការយល់ឃើញរបស់មាណព តែជួនកាលរបៀបកាត់រង ដែលនាយបន្ទូនឯងមានកម្រិតយ៉ាងទាប ម្លោះហើយក៏ចាំស្តាប់សេចក្តីកែតម្រូវរបស់រ៉ន់ជានវិញ ។

នៅពេលអ្នកទាំងឡាយកំពុងជាប់ចិត្តដិតអារម្មណ៍ទៅលើការប្រកួតប្រជែងរហូតភ្លេចការនឿយហត់និងបាយទឹកនេះ មាណពរៀនចេះស្នៀតនីមួយៗយ៉ាងប្រាកដ ។ សិស្សភ្នំទឹកកកចេះតែផ្លាស់ប្តូរវេនប្រយុទ្ធជានិច្ច ទម្រាំគ្រប់ ៦ គូ ផានក្រេបតម្រិះបានសន្ធឹក ។

នាយនឹកឆ្ងល់ម្នាក់ឯងថា:

-ពួកនេះហាត់រៀនយូរហើយម៉េចក៏កម្លាំងខ្សោយម្ល៉េះ? ស្នៀតខ្វះហាក់ឆាយសោះហេតុអ្វីពួកគេសំដែងមិនត្រឹមត្រូវ ?

គួរបញ្ជាក់ថា យុទ្ធសិល្បៈ «ព្រះរូបបង្ក្រាបបិសាច» ជាវិធីហាត់កម្លាំងធាតុដ៏ខ្ពង់ខ្ពស់ប្រចាំភ្នំទៅលីនជឺ ហើយនរណាដែលរៀនចេះយុទ្ធសិល្បៈនេះ តែងមើលឃើញស្នៀតគុនដាវអ្នកដទៃថាងាយស្រួលដកប ហាក់ដូចឡើងលើភ្នំហើយក្រឡេកភ្នែកចុះមកក្រោមដូច្នេះឯង ។ ពេល

តាមកំពុងសញ្ជឹងគិត ស្រាប់តែឮស្នូរប៉ាយវ៉ាន់ផានបោះផាវទៅដី ហើយដកដង្ហើមយ៉ាងវែង ។ សិស្សក្តីទឹកកកមើលមុខគ្នាឡាំងឡង់ព្រោះមិនយល់អាកប្បកិរិយារៀមច្បង ។ ប៉ាយវ៉ាន់ផានបែរសម្លឹងស៊ុផណានដោយទឹកមុខស្រងូតស្រងាត់ក្រៃលែង ។ គាត់ពោលរង្វើរៗ :

-អាក្មេងនេះចូលមកក្រុមយើងពីរបីឆ្នាំសោះ វាមានមូលដ្ឋានយុទ្ធសិល្បៈជំមាំមួន ទោះមិនអាចប្រៀបផ្ទឹមនឹងគ្រូគ្រូមាដែលខំហាត់រៀនជាច្រើនឆ្នាំក៏ដោយក៏គួរស្ញើចវាដែរ ។ វាមានប្រាជ្ញាឈ្លាសវៃណាស់ ធ្វើឲ្យបងហ៊ុងស្រឡាញ់រាប់អានអស់ពីចិត្ត សូម្បីលោកនាយក្រុមក៏លួចញញឹមសរសើរលើវាយ៉ាងមាំដែរ ដោយនឹកថាវានេះហើយដែលអាចលើកស្ទួយកិត្តិនាមក្រុមបានហ៊ុំ ! ...ហ៊ុំ !...

គាត់បញ្ចេញដង្ហើមធំជារៀយៗជាកត្តាបញ្ជាក់នូវការស្តាយស្រណោះដ៏ធំធេង ។ អ្នកក្លាហានពិសុទ្ធប៉ាយវ៉ាន់ផានមានកម្រិតយុទ្ធសិល្បៈខ្ពង់ខ្ពស់និងទស្សនៈត្រឹមត្រូវណាស់ ។ ក្រោយដែលបានបង្ហាត់បង្រៀនកែប្រែកម្រង់ប្អូនរួមគ្រូទាំងដប់ពីរមក គាត់ដឹងថាប្អូនទាំងនេះ ទោះខំហាត់ហ្វឹកហ្វឺនយ៉ាងណាក៏មិនចម្រើនរហូតបានផលដ៏គាប់ប្រសើរដែរ នេះគឺប្រាជ្ញាម្នាក់ៗអន់ខ្សោយពេក ។

គាត់សែនអល់ឯកអួលអាក់ ព្រោះបារម្ភខ្លាចក្រែងគ្មានអ្នកណាប្រកបដោយសមត្ថភាពគ្រប់គ្រានឹងបន្តតំណែងនាយក្រុមទៅអនាគត ។ បើសង្ឃឹមស៊ុផុងយី ឃើញថាមិនកើតទេ ព្រោះវាគ្មានលក្ខណៈជាអ្នកដឹកនាំដ៏សប្បុរសថ្លៃថ្នូរសោះ ។ ប៉ាយវ៉ាន់ផានពិចារណាកាន់តែវែងឆ្ងាយ កាន់តែអាណោចអាធ័មស្រងេះស្រងោចឡើង រហូតភ្លេចរឿងអាស្រូវប្រចាំក្រុមអស់រលីង ។ ស៊ុផណានឃើញប៉ាយវ៉ាន់ផានសម្លឹងមើលនាយដោយស្រទន់ក៏រំភើបញាប់ញ័រ នឹកស្រឡាញ់រាប់អានគាត់ណាស់ ទោះមិនយល់ចិត្តគាត់ក៏ដោយ ។ បរិយាកាសក្នុងខ្ទមស្ងាត់ជ្រៀប...មួយសន្ទុះទើបប៉ាយវ៉ាន់ផានលូកជើងឆ្កឹះផាវដែលធ្លាក់ដីឲ្យខ្ទាតផ្ងោងមកដល់ដៃគាត់ ហើយគាត់ចាប់ផាវជាប់ក្រោកឈរស្រែកខ្លាំងៗ :

- អ្នកក្លាហានមកពីទីណា, សូមអញ្ជើញបង្ហាញខ្លួន កុំពួនយូរពេក !

សិស្សក្តីទឹកកកទាំងអស់ភ្ញាក់ព្រើតនឹកក្នុងដល់ក្រុមឈានល្អ ។ គេផ្ទឹងស្នូរថា :

- បើមានមនុស្សថ្មែកចូលមកម្តេចហ្វូវ៉ាន់យាននិងមិនវ៉ាន់ហ្វូមិនដឹង, មិនឲ្យដំណឹង ? ហើយឥឡូវនេះម៉េចលោកបងប៉ាយដឹងមុនគេ ?

ក្នុងពេលសិស្សក្តីទឹកកកភ្ញាក់ផ្អើលនោះឮស្នូរជាំងៗ ! ហើយមនុស្សពីរនាក់លោតព្រិបដល់មុខអ្នក

តាំងអស់យ៉ាងស្រាលដូចស្រមោល ។ មួយជាប្រុសស្លៀកពាក់ខ្មៅម្នាក់ទៀតជាស្ត្រីស្លៀកពាក់សស្គុស ។ ផនតាំងពីស្តាយផាវខ្មៅមួយសមួយនៅក្រោយខ្នង ឈរយ៉ាងសង្ហាក្នុងពេនកញ្ចាស់ ។ ប៉ាយវ៉ាន់ផានប្រញាប់ក្រឡប់ចុងផាវចុចដី ហើយលើកដៃគោរពព្រមតាំងពោលខ្លាំងៗ:

–គឺជាលោកប្រុសលោកស្រីម្ចាស់ភូមិហានសាំនស៊ូទេតើ ! សូមអញ្ជើញ !

មែន ! បុរសនិងស្ត្រីមួយគូនេះគ្មានរណា ក្រៅពីស៊ីឈីងនិងវ៉ុនយូទេ ។ គេបញ្ចេញទឹកមុខរីករាយលើកដៃគោរពតបវិញ :

–លោកបងប៉ាយខាងក្នុងទឹកកកអញ្ជើញទៅដល់ភូមិហានខ្ញុំ តែយើងឥតបានទទួលសោះ ! សូមមេត្តាអភ័យទោស ។

សិស្សក្តីទឹកកកតាំងប៉ុន្មានដែលធ្លាប់ជួបស៊ីឈីងនិងភរិយានៅភូមិហូវផាន សុទ្ធតែជាប់ឃុំក្នុងក្រុមឈានល្អអស់ទៅហើយ ។ អ្នកនៅទីនេះឥតស្គាល់គាត់ផងទេ គ្រាន់តែឃើញមុខគេភ័យប៉ផ្អុក នឹកថា :

–យើងដុតបំផ្លាញភូមិគេខ្ទេចខ្ទីអស់ តើគេដឹងហើយឬនៅ ?

ប៉ាយវ៉ាន់ផានពោលត្រង់ៗ:

– លាក់បាំងអីពួកខ្ញុំទៅកាន់ភូមិលោកដើម្បីស្វែងរកកូនលោកតែយើងរកមិនឃើញ បានជាដុតភូមិហានលោកខ្ទេចខ្ទីអស់ទៅ ។

ស៊ីឈីងនៅតែញញឹម:

–បាទមានអី, បើភូមិហានខ្ញុំសង់មិនបានមាំមួនធ្វើឲ្យទើសភ្នែកលោក, លោកដុតចោលជំនួសខ្ញុំជាការប្រសើរម្យ៉ាងដែរ ។ ខ្ញុំត្រូវអរគុណលោកបងដែលបានបណ្តេញមាន់ទាពីភូមិខ្ញុំអស់មិនឲ្យស្លាប់មួយថែមទៀតណា ! ត្រង់នេះបញ្ជាក់ឲ្យខ្ញុំឃើញច្បាស់ថាលោកបងមានមេត្តាធម៌ណាស់ ។

ប៉ាយវ៉ាន់ផានតបបែបព្រងើយ :

– សត្វធាតុនៅក្នុងភូមិហានលោកឥតមានទោសពៃរ៍អ្វីសោះ យើងខ្ញុំកាប់សម្លាប់មិនរួចទេ ។ ហេតុនេះសុំលោកកុំព្រួយ, មិនត្រូវអរគុណទេ ។

**(នៅមានត)**

ដកល់ទុកតាមលេខ ៣០៩ ចុះថ្ងៃទី ២២ ៤ - ៧០ បោះពុម្ពលើកទី ១ ចំនួន ២០០០ ច្បាប់

Khmer Story Lovers